
Kids of Destiny
Rescuing the Forgotten
www.kidsofdestiny.org

## 2.03 **ជីវិតរបស់យ៉ូសែបនៅស្រុកអេស៊ីព្ទ ភាគ ១**

លោកយ៉ូសែបគឺជាកូនប្រុសសំណព្វ របស់ឪពុកគាត់ឈ្មោះយ៉ាកុប។ លោកយ៉ាកុបថែមទាំងបានធ្វើអាវធំមួយឲ្យយ៉ូសែប ដែលមានពណ៌ស្រស់ឆើតឆាយ ដើម្បីបង្ហាញថា យ៉ូសែបមានភាពពិសេសចំពោះគាត់ខ្លាំង ណាស់។ ឃើញដូច្នោះ បងៗរបស់យ៉ូសែបច្រណែននឹងគាត់ណាស់។ ពួកគេបានស្អប់យ៉ូសែប។ នៅថ្ងៃមួយ បងៗយ៉ូសែបបានលក់ លោកយ៉ូសែបទៅឲ្យឈ្មួញអេស៊ីព្ទ ដែលពួកគេមានគ្នាពីរបីនាក់។ បងៗរបស់យ៉ូសែបបានប្រាប់ឪពុករបស់ពួកគេថា យ៉ូសែបបានស្លាប់បាត់ហើយ។ វាជាថ្ងៃសោកសៅណាស់សម្រាប់យ៉ាកុប។ ប៉ុន្តែលោកយ៉ូសែបមិនបានស្លាប់ទេ។ នៅពេលដែលឈ្មួញទៅដល់ស្រុកអេស៊ីព្ទ ពួកគេបានលក់យ៉ូសែបទៅឲ្យមន្ត្រីជនជាតិអេស៊ីព្ទម្នាក់ឈ្មោះ ប៉ូទីផារ។ លោកប៉ូទីផារជាអ្នកធ្វើការឲ្យព្រះចៅផារ៉ោន ជាស្ដេចនៃស្រុក អេស៊ីព្ទ។ ដោយសារព្រះគង់នៅជាមួយលោកយ៉ូសែប ហើយមើលថែរក្សាគាត់ជានិច្ច លោកយ៉ូសែបបានទទួលជោគ ជ័យក្នុងគ្រប់កិច្ចការដែលគាត់បានធ្វើទាំងអស់។ លោកប៉ូទីផារបានកត់សម្គាល់ឃើញថា លោកយ៉ូសែបទទួលជោគជ័យ និងរបៀបដែលព្រះគង់នៅជាមួយគាត់ ដូច្នេះគាត់បានឲ្យយ៉ូសែបនូវការងារសំខាន់ជាងគេមួយទៀត។ ឥឡូវនេះ លោកយ៉ូសែបជាអ្នកមើលការខុសត្រូវ លើផ្ទះទាំងមូលរបស់ប៉ូទីផារ និងអ្វីៗទាំងអស់ដែលគាត់មាន។ បន្ទាប់មកប៉ូទីផារបានចាប់ផ្ដើមមានរឿងល្អៗ កើតឡើងចំពោះគាត់។ ដំណាំ និងសត្វរបស់គាត់ចាប់ផ្ដើមល្អប្រសើរជាងមុន។ ប៉ូទីផារបានប្រគល់ភារកិច្ចថែមទៀតដល់យ៉ូសែប។ លោកយ៉ូសែបមិនចាំបាច់ត្រូវព្រួយបារម្ភអំពីរឿងអ្វីទាំងអស់។ នៅថ្ងៃមួយភរិយារបស់ប៉ូទីផារចង់ឲ្យយ៉ូសែបចំណាយពេលខ្លះជាមួយនាង។ លោកយ៉ូសែបបានដឹងថា នេះមិនមែនជាការងាររបស់គាត់ទេ។ លោកប៉ូទីផារនឹងមិនរីករាយទេ ប្រសិនបើគាត់ដឹងថា យ៉ូសែបកំពុងចំណាយពេលជាមួយប្រពន្ធរបស់គាត់។ ដូច្នេះ លោកយ៉ូសែបបានព្យាយាមរត់ចេញពីនាង។ តែនាងបានចាប់ទាញយកអាវរបស់យ៉ូសែប ខណៈពេលដែលគាត់ព្យាយាមរត់។ ក្រោយមកនាងបានប្រាប់ប្ដីរបស់នាងឈ្មោះ ប៉ូទីផារថា យ៉ូសែបបានចាប់នាង ហើយនាងក៏បានចាប់យកអាវរបស់យ៉ូសែបនៅក្នុងការតស៊ូ ដើម្បីរត់គេចខ្លួនពីយ៉ូសែបទៅ។ នាងបាននិយាយកុហកប្រាប់គាត់ ប៉ុន្តែប៉ូទីផារបានជឿប្រពន្ធរបស់គាត់។ លោកប៉ូទីផារបានខឹងនឹងយ៉ូសែបណាស់ ហើយក៏ចាប់យ៉ូសែបដាក់ទៅក្នុងគុកទៅ។ ទោះជាយ៉ាងណាក៏ដោយ សូម្បីតែនៅក្នុងគុកក៏ព្រះអម្ចាស់បានប្រទានពរដល់យ៉ូសែបដែរ ហើយមើលថែរក្សាគាត់ដដែល។ អ្នកយាមគុកបានទុកចិត្តនឹងយ៉ូសែប ហើយបានតែងតាំងគាត់ឲ្យមើលការខុសត្រូវលើអ្នកទោសឯទៀត។ មានបុរសពីរនាក់ទៀតនៅក្នុងគុក ដែលបានធ្វើឱ្យស្ដេចនៃស្រុកអេស៊ីព្ទខឹង។ បុរសម្នាក់ជាអ្នកថ្វាយពែង ដែលបានបម្រើស្ដេចដោយយកពែងទៅជូនស្ដេច ។ ម្នាក់ទៀត ជាអ្នកដុតនំប៉័ងដែលចម្អិនសម្រាប់ព្រះរាជា។ ក្នុងអំឡុងពេលដែលពួកគេនៅក្នុងគុក ពួកគេបានយល់សុបិន្ត ។ លោកយ៉ូសែបបានសុំឱ្យពួកគេប្រាប់គាត់អំពីសុបិន្តនោះ ។ គាត់បាននិយាយថា "ព្រះនឹងប្រាប់ខ្ញុំពីអត្ថន័យនៃសុបិន្តនោះ" ។ នាយវិសេសថ្វាយពែងនោះបានប្រាប់យ៉ូសែបថា "ខ្ញុំបានសុបិន្តអំពីដើមទំពាំងបាយជូរមួយដើម ដែលមានមែកបីនៅលើនោះ ។ មានផ្លែទំពាំងបាយជូរខ្លះបានដុះនៅលើមែកនោះ ។ ហើយខ្ញុំបានច្របាច់ទឹកទំពាំងបាយជូរដាក់ចូលទៅក្នុងពែងរបស់ស្ដេច ហើយបានថ្វាយទៅឱ្យទ្រង់" ។ លោកយ៉ូសែបមានប្រសាសន៍ថា៖ «សុបិន្តនេះមានន័យថា ក្នុងរយៈពេលបីថ្ងៃទៀត អ្នកនឹងត្រូវបានដោះលែងពីគុក ហើយវិលត្រឡប់ទៅធ្វើការរបស់អ្នកវិញ ដែលបម្រើស្ដេចដោយយកពែងទៅថ្វាយស្ដេចដដែល»។ អ្នកដុតនំក៏ប្រាប់យ៉ូសែបអំពីសុបិន្តរបស់គាត់ ។ គាត់និយាយថា "ខ្ញុំសុបិន្តឃើញថា មានកន្ត្រកបីនៅលើក្បាលរបស់ខ្ញុំ ។ មាននំល្អៗនៅក្នុងកន្ត្រកទាំងនោះ សម្រាប់ថ្វាយព្រះចៅផារ៉ោនជាស្ដេច។ បន្ទាប់មក បក្សីក៏មកចឹកស៊ីនំពីកន្ត្រកនោះបាត់ទៅ ។ លោកយ៉ូសែបបាននិយាយស្រាយសុបិន្តនោះមានន័យថា ក្នុងរយៈពេលបីថ្ងៃទៀត ស្ដេចនឹងសម្លាប់អ្នកហើយ។ គាត់នឹងត្រូវព្យួរនៅលើដើមឈើ ហើយសត្វបក្សីនឹងមកចោមរោមស៊ីគាត់។ នេះជាអ្វីដែលបានកើតឡើង! លោកយ៉ូសែបបានឮសេចក្ដីពិតពីព្រះអំពីសុបិន្តទាំងនេះ! **(លោកុប្បត្តិ ៣៩ និង ៤០)**

2.03 **ជីវិតរបស់យ៉ូសែបនៅស្រុកអេស៊ីព្ទ ភាគទី ១**
**សេចក្តីណែនាំសម្រាប់គ្រូបង្រៀន កំណត់សម្គាល់**:

1) លោកយ៉ូសែបត្រូវបានគេលក់ទៅឱ្យលោកប៉ូទីផារ ដែលជាមន្ត្រីជនជាតិអេស៊ីព្ទម្នាក់ ដែលធ្វើការឱ្យស្តេចអេស៊ីព្ទ ។
2) ព្រះអម្ចាស់ទ្រង់គង់នៅជាមួយលោកយ៉ូសែប ហើយបានថែរក្សាគាត់ ។ លោកប៉ូទីផារបានប្រគល់ការងារសំខាន់ដល់យ៉ូសែប ដើម្បីមើលថែរក្សាផ្ទះរបស់គាត់ ។
3) លោកយ៉ូសែបនៅតែបំពេញការងារបានល្អ ។ ប៉ូទីផារបានឲ្យការងារគាត់ថែមទៀត ។
4) ភរិយារបស់លោកប៉ូទីផារបានខឹងនឹងយ៉ូសែប ពីព្រោះគាត់មិនចំណាយពេលជាមួយនាងទេ ដូច្នេះនាងបានកុហកប៉ូទីផារ ។ នាងបាននិយាយថា យ៉ូសែបបានចាប់នាងជាច្រើនដង ដូច្នេះប៉ូទីផារខឹងនឹងយ៉ូសែបណាស់ ហើយក៏ចាប់គាត់ដាក់គុកបាត់ទៅ ។
5) នៅក្នុងគុកមានអ្នកថ្វាយពែងម្នាក់ និងអ្នកដុតនំថ្វាយស្តេចម្នាក់ ។ បុរសទាំងពីរនាក់នេះបានធ្វើការឲ្យព្រះរាជា ។ ពួកគេបានយល់សុបិន្ត ដែលពួកគេមិនយល់ ។ ពួកគេបានសួរយ៉ូសែបថា តើគាត់អាចប្រាប់ពួកគេពីអត្ថន័យសុបិន្តនោះបានទេ ។
6) លោកយ៉ូសែបបាននិយាយថា ព្រះជ្រាបពីអត្ថន័យនៃសុបិន្តទាំងនោះ ដូច្នេះគាត់អាចប្រាប់ពួកគេពីអត្ថន័យនៃក្តីសុបិន្តរបស់ពួកគេបាន ។

**សំណួរ**

1) តើលោកយ៉ូសែបត្រូវបានលក់ទៅឲ្យអ្នកណានៅស្រុកអេស៊ីព្ទ?
2) តើព្រះទ្រង់បានបង្ហាញយ៉ាងដូចម្តេចថា លោកយកចិត្តទុកដាក់ចំពោះយ៉ូសែប?
3) តើអ្វីដែលធ្វើឱ្យប្រពន្ធលោកប៉ូទីផារភូតកុហក?
4) តើអ្នកណានៅក្នុងគុកជាមួយយ៉ូសែប?
5) តើអ្នកថ្វាយពែង និងអ្នកដុតនំមានបញ្ហាអ្វី?
6) តើលោកយ៉ូសែបអាចប្រាប់ពួកគេពីអត្ថន័យនៃក្តីសុបិន្តរបស់ពួកគេបានទេ?

**ចម្លើយ**

1) លោកយ៉ូសែបត្រូវបានលក់ទៅឲ្យលោកប៉ូទីផារ ដែលជាអ្នកធ្វើការឲ្យស្តេចនៅស្រុកអេស៊ីព្ទ ។
2) ព្រះទ្រង់បានជួយលោកយ៉ូសែប ឲ្យធ្វើកិច្ចការរបស់គាត់បានយ៉ាងល្អ ដូច្នេះប៉ូទីផារបានប្រគល់ការងារសំខាន់ដល់យ៉ូសែប ដើម្បីមើលថែរក្សាផ្ទះរបស់គាត់ ។
3) ភរិយារបស់លោកប៉ូទីផារបានខឹងនឹងយ៉ូសែបណាស់ ហើយបាននិយាយកុហក ពីព្រោះយ៉ូសែបមិនបានចំណាយពេលជាមួយនាង ។
4) អ្នកថ្វាយពែង និងអ្នកដុតនំម្នាក់បាននៅក្នុងគុកជាមួយយ៉ូសែប ។
5) អ្នកថ្វាយពែង និងអ្នកដុតនំបានយល់សុបិន្ត ដែលពួកគេមិនយល់ន័យ ។
6) ត្រូវហើយ ។ ព្រះទ្រង់បានជួយយ៉ូសែបឱ្យបកស្រាយអត្ថន័យនៃសុបិន្តរបស់ពួកគេ ។



Kids of Destiny®
Reaching the Next Generation

www.kidsofdestiny.org